អាចារ្យក្រឡេកចុះឡើងពិនិត្យទៅវាលក្រៅ តាមរយៈបង្អួចធំទាំងប្រាំបី។ ចុងក្រោយតាដួងចាប់ផ្ដើមដើរមួយៗចាកចេញទៅរកបង្អួចត្បូងនៅខាងឆ្វេងដៃ។

នៅទីនោះ មានចេកចេញផ្កាពីរបីដើមដុះផ្ដុំគ្នា។ អាចារ្យចង្អុលទៅទីនោះធ្វើឲ្យសេដ្ឋីនីស្រែកហៅខ្លាំងៗភ្លាម៖

«អាកុកអាគុង!»

បាវទាំងពីររត់ចូលមកវិញ អាចារ្យក៏បង្គាប់ថា៖

«ឯងទៅក្រៅបង្អួចនោះ នាំកម្មករជីកដីឱ្យបាន៦ហត្ថចុះក្រោម!»

កូនព្រាវទាំងពីរក៏ចាប់ផ្ដើមចេញទៅក្រៅនាំគ្នីគ្នាចាត់ការជីកតាមដែលអាចារ្យបង្គាប់។ នៅក្នុងឯណេះ អាចារ្យត្រូវបានស្ត្រីអភិជនប្រណាមអង្វរខ្សឹបខ្សៀវ៖

«លោកគ្រូ តើមានមន្តអ្វីឱ្យព្រាយអសារបង់ពីលោកនេះទៅដែរ?»

អាចារ្យធ្វើមុខមាំស្ដីតបមួយៗ៖

«កម្មពៀរនិងផលបុណ្យ មិនបាត់បង់ជារៀងតទៅ ធ្វើល្អបានស្ងប់ធ្វើសម្អប់បានព្រួយ!»

អភិជននៅទ្រឹងស្ងៀមពីក្រោយខ្នងគ្រូទំនងថាកំពុងគិតពីកម្មផលរបស់ខ្លួន។

ភ្លាមនោះបម្រើស្រីពីរនាក់ឈ្មោះឈុំនិងសាយដែលទើបក្រោមពីសន្លប់ រត់មកឱបជើងចៅហ្វាយយំយែកថា ៖

«ជំទាវជាទីគោរព យាយអិនបានស្លាប់បាក់កទៅហើយ!»

ជំទាវទន់ជើងអង្គុយកណ្ដាលចំណោមខ្ញុំកំដរដោយភ័យរន្ធត់។

ចំណែកឯអាចារ្យបានត្រឹមសើចតិចៗងាកទៅសួរកូនសិស្សដែលកំពុងតែឱបសៀវភៅធម៌។

«អាមន្ត ឯងយល់បែបណារឿងរបស់យាយអិន!»

នាយមន្តគ្រុនៗតបឆ្លើយ៖

«បាបបុណ្យមានវេន!»

សេដ្ឋីនីយំសស្រាក់ ហើយនិយាយដោយទន់ខ្លួនថា៖

«ខ្ញុំធ្វើម្ដេចរំដោះកម្មនេះ? នាងរម្យនានិងប្ដីខ្ញុំជាអ្នកសាងកម្មមុន បានជាអ្វីៗក្លាយជាបែបនេះ! ចំណែកយាយអិន ដែលសម្លាប់នាងព្រោះគាត់គិតអាណិតទុក្ខវេទនាផ្លូវចិត្តរបស់ខ្ញុំ!»

អាចារ្យមិនចង់ឱ្យបាវព្រាវដឹងរឿងនេះច្រើន ក៏ងាកទៅរក ខ្ញុំស្រីៗគ្រប់គ្នាបញ្ជាថា៖

«ឯង ចូរនាំគ្នារកអ្នកភ្លុកមករៀបចំខ្មោចយាយអិនតាមរបៀបភូមិស្រុក! អ្នកណាប្រឹងដុតដៃជើងធ្វើបុណ្យអ្នកនោះនឹងរួចបណ្ដាសាកម្មដែលបានធ្វើលើព្រាយរម្យនា!»

ខ្ញុំទាំងអស់រត់ទៅស្រ ចាត់ចែងបុណ្យយាយ។

អាចារ្យប្រាប់ឱ្យជំទាវចូលបន្ទប់ជំនុំមួយ ហើយស្រដីលាក់ការណ៍តែពីរប្រាណ មានអាមន្តជាសិស្សនៅយាមមាត់ទ្វារឱ្យ។

«តើជំទាវបានសម្លាប់នារីអភ័ព្វនោះឬអ្វី?!»

«មិនបានធ្វើទេលោកគ្រូ!»

«ចុះហេតុអ្វីភិតភ័យ?»

«រឿងហេតុកើតឡើងក្នុងគេហៈនៃខ្ញុំ ហេតុអ្វីអាចរំងាប់មិនភិតភ័យបាន?!»

«ចូរអង្គជំទាវប្រាប់យើងរឿងអតីតគ្រប់យ៉ាងមិនអាចបំផ្លើសឬសូម្បីកុហកកន្លែងណាបានទេ ព្រោះព្រាយក៏នៅឯណោះកំពុងតែនៅចាំស្ដាប់ដូចគ្នា! កាលបើវាឮពាក្យណាមួយកុហក វាមុខតែកាចសហាវខ្លាំងឡើងព្រោះការសុខចិត្ត!»

ជំទាវអង្គុយនៅកៅអីម្ខាងគិតរំពៃដោយទឹកមុខមាំ។ ខណៈអាចារ្យកំពុងដើរប្រោះព្រំសូត្រសិល៍្បជុំវិញនេះ អម្ចាស់ស្រដីឡើងមួយៗថា៖

«ខ្ញុំគ្មានលាក់បាំងអីទៀតទេលោកគ្រូ! កាលណោះបើវាមិនស្លាប់ ខ្ញុំជាអ្នកស្លាប់! ព្រាយនេះដើមឡើយជាអ្នកបម្រើនៅក្នុងផ្ទះរបស់ខ្ញុំ ម្ដាយវាបានយកមកលក់តាំងពីអាយុ១៤ឆ្នាំ ព្រោះជាប់បំណុលគេនិងមានប្ដីចុង! នៅនឹងខ្ញុំ ដោយសារខ្ញុំមិនមានកូនម្នាក់ ក៏ផ្ទុកចិត្តអាណិតស្រលាញ់ខ្ញុំមិនឱ្យវាទៅធ្វើស្រែចម្ការដូចព្រាវឯណាផ្សេង ឱ្យតែនៅក្នុងម្លប់ និងតុបតែងប្រគល់អលង្ការ អាវសំពត់ឱ្យមានមិនខ្វះប្រើ ប៉ុន្តែវាជាយុវនារីចិត្តធំ ក្រោយមកមិនបានប៉ុន្មាន រស់នៅទំនេរសុខស្រួលពេក ក៏លុះចិត្តហ៊ានមកធ្វើនូវអំពើដែលមិនសមរម្យក្នុងនាមជាអ្នកបម្រើ! វាបានពង្វក់

ស្នេហ៍ទៅកាន់ស្វាមីរបស់ខ្ញុំជារឿយៗ ដូច្នេះហើយបានជាថ្ងៃមួយអ្នកបម្រើក្នុងផ្ទះ បានឃើញវាចេញពីបន្ទប់ធ្វើការរបស់លោកអភិបាល! រឿងមួយនេះលេចឮពេញភូមិតែខ្ញុំនៅមិនជឿសោះឡើយ ដោយសារតែខ្ញុំនិងប្ដីមានចិត្តស្មោះមកយូរហើយ មួយវិញទៀតខ្ញុំតែងគិតថា នាងរម្យនាគឺជានារីដែលមានរូបស្អាតមកពីឆ្ងាយគ្មានសាច់ញាតិ ត្រូវខ្ញុំទំនុកបម្រុងដូចកូនធម៌ ប្រុងថាចង់ផ្សងផ្ដើមឱ្យមានប្ដីជាគហបតី នាម៉ឺនមួយនឹងគេ បានជារឿងនេះបណ្ដាលឱ្យអ្នកបម្រើផ្សេងៗមានគំនិត ច្រណែននិន្ទា អាចថាគេនាំគ្នាបង្កើតជារឿងកុហកឡើងមកឲ្យខ្ញុំធ្វើការសង្ស័យហើយស្អប់ខ្ពើមព្រមទាំងបណ្ដេញចេញពីទីនេះ។ រហូតដល់ថ្ងៃមួយដែលខ្ញុំបានឃើញការជាក់ស្ដែង ខ្ញុំហួសចិត្តណាស់ក៏បានចូលទៅសួរនាំប្ដីរបស់ខ្ញុំថា តើនឹងចង់បាននាងរម្យនាជាប្រពន្ធចុងឬក៏អ្វី? ស្រាប់តែមនុស្សស្រីដ៏ក្មេងសេចក្ដីម្នាក់នេះ មិនត្រឹមតែមិនបញ្ចេញនូវការដឹងគុណព្រមគោរពចំពោះម្ចាស់បុណ្យ ឲ្យបាយទឹកខ្លួនចិញ្ចឹមជីវិតខ្លួន ថែមទាំងមានបំណងចង់ចាក់រុកឆ្កឹះឆ្កៀលឲ្យលោកអភិបាលធ្វើទុក្ខបុកម្នេញខ្ញុំទៀត! នាងនិយាយថានាងមានកូនហើយ តែខ្ញុំនេះរៀបការជាង១០ឆ្នាំ មិនមានផ្ទៃពោះសូម្បីម្ដងណា ហើយថាខ្ញុំជាអ្នកធ្វើបាបឲ្យនាងវេទនា! ចាប់ពីពេលនោះមកលោកអភិបាលក៏បានឱកាស នៅក្នុងការបង្ហាញបើកចំហថា ពួកគេគឺជាគូស្នេហ៍នឹងគ្នាត្រៀមតែរៀបចំធ្វើពិធីទទួលនាងធ្វើជាស្រីកំណាន់ចេញមុខឈានដល់ឋានៈជាប្រពន្ធចុងនៅថ្ងៃអនាគតបើកូនកើតមក! រឿងនេះធ្វើឲ្យខ្ញុំកើតទុក្ខ ជាខ្លាំងរហូតដល់កើតជំងឺឈឺស្គមរីងរៃសល់ដង្ហើមផ្ដឹកៗ! ប្រុសៗនៅនគរនេះ ប្រក្រតីគេមានប្រពន្ធចុងទុកថាជារឿងធម្មតា ប៉ុន្តែនាងរម្យនាបានដាក់បណ្ដាសាមកលើខ្ញុំ ប្រាប់អ្នកស្និទ្ធស្នាលនាងខ្ញុំទាំងឡាយថា ខ្ញុំនឹងវិនាស ព្រមទាំងរកកលវិធីឲ្យលោកអភិបាលជាប្ដីរបស់ខ្ញុំបណ្ដេញពួកគេចេញម្ដងម្នាក់ ម្នាក់ចុងក្រោយមិនអាចទទួលយកនូវអនាគតស្រពេចស្រពិល ហើយមានអ្នកមកប្រាប់យាយអិនថា នាងរម្យនាពិតជាមានកូនជាមួយនឹងលោកអភិបាលទាំងដែលខ្ញុំរៀបការជាច្រើនឆ្នាំមិនអាចមានកូនជាមួយគាត់បានដូច្នេះហើយបានជាខ្ញុំសម្រេចចិត្តបញ្ចប់ជីវិតខ្លួនឯង! នៅពេលនោះយាយអិនដែលជាអ្នកស្មោះត្រង់ជាមួយខ្ញុំបានរកវិធីដើម្បីកម្ចាត់នាងរម្យនា!»

បានស្ដាប់ឮពាក្យពេចន៍ទាំងអស់នេះហើយអាចារ្យដួងយល់សេចក្ដីទាំងអស់ក៏ចាប់ផ្ដើមធ្វើជា ងាកទៅនិយាយជាមួយនឹងខ្មោចនៅក្នុងកូនឃ្លោកថា៖

«ហៃព្រាយរមនា! តើអ្វីដែលជំទាវអម្ពរបាននិយាយឡើងនេះ គឺជាសេចក្ដីពិតដែរឬទេ? បើសិនជាមិនពិតទេ យើងឲ្យឱកាសឯងមួយនៅក្នុងការរើខ្លួនរួចពីបាលីឃ្លោកនេះបាន! មានន័យថាបើសិនជាឯងជាអ្នករងអំពើអយុត្តិធម៌ត្រូវគេមួលបង្កាច់ហើយឯងមិនបានធ្វើអំពើល្មិតល្មើងមកលើគ្រួសារអ្នកមានគុណ មិនបានបំបែកបំបាក់ប្ដីប្រពន្ធរបស់គេឯងនឹងអាចរើខ្លួនពីបាលីដី

ឃ្លោកនេះចេញមកក្រៅតាមអំពើចិត្តបានក្នុងពេលបីថ្ងៃ តែបើសិនជាឯងពិតជាមានកម្មដូចពាក្យជំទាវនិយាយ ឯងហ៊ានស្បថទេថា នឹងរស់នៅទីនេះជារៀងរហូតតទៅ?»

ស្រាប់តែភ្លាមៗនោះ ផ្ទៃបន្ទប់ជំនុំទាំងមូលក៏ត្រូវកញ្រ្ជោលបោកបាច។ សូម្បីតែបណ្ដាផ្កាភ្ញីតាំងលម្អនៅលើពិតានទាំងអស់រំយោលចុះឡើងក៏ត្រូវកន្ត្រាក់ជ្រុះដោយអំណាចនៃអ្វីម្យ៉ាងដែលពិបាកមើលឃើញ។

ចំពោះអម្ចាស់នាងហាក់បីដូចជាមិនខ្លាចអ្វីទាំងអស់ ដោយសារខ្លួនបាននិយាយនូវអ្វីដែលជាសេចក្ដីពិត និងរឿងដែលបានជាធ្លាប់បានកើតឡើងមិនមានការកុហកបោកប្រាស់អ្វី។

ស្ដ្រីអភិជននៅអង្គុយរង់ចាំស្ដាប់ការឆ្លើយតបរបស់សត្រូវអរូបនៃខ្លួន ដែលរងកញ្រ្ជោលចុះឡើងប៉ុន្តែមិនបែកឃ្លោកចេញមកបាន។

ជំទាវនិយាយឡើងដោយជូរចត់ថា៖

«នាងរម្យនា វាសនាតទៅ គឺនាងនឹងចេញពីទីនេះមិនរួចជារៀងរហូត ពីព្រោះនាងគឺជាអ្នកបង្កការឈឺចាប់មកលើគ្រួសារមួយនេះ! អកតញ្ញូរបស់នាង នឹងធ្វើឲ្យនាងបន្តរស់នៅអស់កប្បទៅដោយវេទនានៅក្នុងភាពងងឹតតទៅ!»

លោកជំទាវអម្ចាស់និយាយបែបនេះដោយទឹកមុខស្ងួតស្ងប់ លែងភ័យខ្លាចលើអ្វីទាំងអស់។

«ប៉ុន្តែឯងជាអ្នកសម្លាប់ប្ដីរបស់ឯង តើឯងគិតរួចកម្មយ៉ាងម៉េចបាន?»

ព្រាយស្រែកយំសន្ធាប់ទាំងខឹងសម្បាពីក្នុងឃ្លោកចេញមកក្រៅ ធ្វើឲ្យអាចារ្យនិងសិស្សងាកមុខមកសម្លឹងអម្ចាស់ដោយភ្ញាក់ផ្អើល។

ត្រូវម្នាក់ៗសម្លឹងមករង់ចាំចម្លើយ ជំទាវអម្ចាស់ស្រក់ទឹកភ្នែកដោក ហើយលើកដៃជូតមុខព្រមទាំងនិយាយសារភាព៖

«ខ្ញុំពិតជាបានសម្លាប់លោកអភិបាល ដោយសារតែខ្ញុំមិនព្រមឲ្យថ្នាំសង្កូវទៅគាត់ព្យាបាល ថែមទាំងមិនបានហៅពេទ្យមកកែរោគឱ្យគាត់! ប៉ុន្តែគាត់មានជំងឺដោយខ្លួនឯងគឺជាជំងឺកាមរោគធ្ងន់ធ្ងរដែលខ្ញុំមានសេចក្ដីអាម៉ាស់នៅក្នុងការហៅពេទ្យហ្មឲ្យមកមើលគាត់! សូម្បីតែខ្លួនខ្ញុំផ្ទាល់រហូតដល់ពេលនេះក៏រងបន្តនូវជំងឺស្នេហាសហាយស្មន់មិនឈប់ឈររបស់គាត់! ខ្ញុំក៏មិនដឹងរស់បានដល់ពេលណាដែរ! ដូច្នេះហើយដើម្បីកិត្តិយសគ្រួសារខ្ញុំមិនបានហៅអ្នកណាមកព្យាបាលគាត់ បើឯងចាត់ទុកថា នេះគឺជាបាបកម្មរបស់ខ្ញុំ ចុះគាត់? ហើយបើសិនជាខ្ញុំមានបាបកម្មមែន

ក៏ខ្ញុំមិនខ្លាចនៅក្នុងការចុះទៅឋាននរកដែរប៉ុន្តែខ្ញុំត្រូវតែការពារកិត្តិយសវង្សត្រកូលនេះ មិនអាចឲ្យហ្លួងឬអ្នកដទៃដឹងថាប្តីរបស់ខ្ញុំមានស្ត្រីរាប់សិបរយនៅខាងក្រៅ ផ្ទុកនូវជំងឺកាមគុណយ៉ាងសាហាវជាទីអាម៉ាស់សម្រាប់វង្សត្រកូលនោះទេ!»

អាចារ្យដួងងក់ក្បាលយល់ស្របហើយក៏បាននិយាយឡើងថា៖

«ឱ អ្នកទាំងពីរ! យើងនេះជាគ្រូមានលទ្ធភាពចាប់ខ្មោចព្រលឹងនានាប៉ុន្តែយើងមិនមានលទ្ធភាពក្នុងការកាត់ក្តីថាអ្នកណាត្រូវអ្នកដែលខុសអ្វីអាក្រក់អ្វីខ្មៅនោះទេ! បើមនុស្សគ្រប់គ្នាធ្វើអ្វីមួយខ្លួនឯងយល់ថាស្ងប់ចិត្តហើយគ្មានចាំបាច់ត្រូវការគ្រូណាមកជួយពន្យល់ដោះស្រាយផ្តល់ឱវាទដដែល! »

«លោកគ្រូ នៅមានរឿងដែលខ្ញុំមិនស្កប់ចិត្ត» ជំទាវអម្ពរបាននិយាយឡើង

«គឺរឿងយាយអិនដែលគាត់ស្រឡាញ់ខ្ញុំពេក ព្រោះតែគាត់ការពារខ្ញុំ មិនចង់ឃើញខ្ញុំធ្វើអត្តឃាតម្តងជាពីរដង ទីបំផុតទោះណាជាគាត់បានកាន់សីលប្រាំតាំងពីដើមមកប៉ុន្តែដោយហេតុតែមិនចង់ឲ្យខ្ញុំ រស់នៅរងទុក្ខវេទនាឃើញអំពើក្បត់របស់ប្តីខ្លួនឯង ដូច្នេះគាត់រកវិធីដើម្បីកម្ចាត់ស្រីព្រាយនេះឡើង! មិនសមណាចុងក្រោយអ្នកដែលត្រូវកាច់កស្លាប់មិនមែនខ្ញុំប៉ុន្តែគឺគាត់!»

អាចារ្យដួងបានពន្យល់ឡើងថា៖

«ម្នាលជំទាវអើយ វេនកម្មលើលោកយើងនេះពិបាកឲ្យយើងស្មានបានដឹងថា តើយាយអិនធ្លាប់បានធ្វើអ្វីខ្លះ ហើយលោកជំទាវបានធ្វើអ្វីខ្លះ! រឿងទាំងអស់សុទ្ធតែមានហេតុនិងផលរបស់វា! ចូរលះបង់ការងាកត្រលប់ក្រោយ កុំស្តាយក្រោយដែលអ្វីៗដែលបានកើតឡើងរួចហើយគិតពីផ្លូវមុខ ថាតើលោកជំទាវចង់បានអនាគតជាតិបែបម៉េច? ចូរសន្សំគំនិតពីពេលនេះតទៅក្រែងល្អជាង!»

«តើខ្ញុំត្រូវសន្សំយ៉ាងម៉េចទៅលោកគ្រូ? បើខ្ញុំទៅបួស តើអ្នកណាជាអ្នកថែរក្សាគេហដ្ឋាននេះ?»

«លោកជំទាវជាអ្នកសម្រេចចិត្តខ្លួនឯង ខ្ញុំមិនអាចឲ្យយោបល់អ្វីទាំងអស់!»

ថាហើយអាចារ្យក៏បានដើរចេញទៅក្រៅទ្វារបោយដៃ ហៅនាយកុកនិងនាយគុងថា៖

«ចូរឯងទៅ រៀបចំកម្មវិធីប្រមូលផ្កាឲ្យបាន១ពាន់សន្លឹក និងដីខ្សាច់ក្រួសថ្ម ជាតិល្បាយគ្រប់យ៉ាងក្នុងផែនដីដែលយើងជាន់នៅ»

ល្ងាចនោះពិធីបានចាប់ផ្ដើមឡើង ដោយអាចារ្យបានដាក់ឃ្លោកមួយ ដែលមានចងយុំឃាំងទុកនូវព្រលឹងស្រីព្រាយទៅក្រោមរណ្ដៅជ្រៅដែលជីកបាន។

លុះដាក់វិញ្ញាណទៅនៅក្រោមដីនោះហើយក៏អាចារ្យដួងបានទាមទារយកចង្កៀងចំនួនបួនមកដាក់អមជាមួយ មានអុចប្រេងភ្លឺ រួចទើបលោកបង្គាប់ឲ្យដាក់ល្បាយដីទាំងនោះពីលើកប់លុបទាំងមានពន្លឺ។

រួចរាល់ទើបចាក់ស្រទាប់ផ្កា១ពាន់ចូលតាមពីក្រោយហើយរោយដីវាយបង្កប់ផ្នូនពេលគាត់សូត្រនូវធម៌ជាច្រើនបទបន្ថែមពីលើការវាយបង្ហាប់បិទរណ្ដៅ។

អ្នកទាំងអស់គ្នានៅទីនេះសុទ្ធតែឮសំឡេងស្រែករោទ៍តវ៉ាឈឺចាប់ ដូចក្នុងក្ដីរំពឹងថាចង់បានឱ្យមានការដោះលែងចេញវិញ។

«យើងមិនចង់នៅទីនេះទេ ដោះលែងយើង!»

អាចារ្យដួងមុនពេលចាកចេញបាននិយាយផ្ដាំថា ដើម្បីឲ្យវាលែងស្រែកបានជារៀងរហូតម្ចាស់ផ្ទះត្រូវតែហូបបួសនិងសូត្រធម៌ឲ្យបានទៀងទាត់ ទើបព្រលឹងដែលមានគំនុំមួយនេះស្ងប់ចិត្តម្ដងបន្តិចៗ លែងចងចាំបាននូវអតីតកាលឈឺចាប់ ពុំនោះទេវិញ្ញាណនេះ ថ្ងៃណាមួយនោះពុះកញ្ជ្រោលអាចចាកចេញពីដីនេះវិញបាន។

ចាប់តាំងពីពេលនោះមកគេតែងតែឃើញសេដ្ឋីនីហូបបួសជាប្រចាំនិងសូត្រធម៌ធ្វើបុណ្យដាក់ទាន រហូតដល់សំឡេងស្រែកក្រោមបាលីចង្កៀងប្រេងបួន ក្លាយជាពាក្យចចាមអារ៉ាមសឹងសាបរលាបចំណេរក្រោយៗមក។

ចំណេរក្រោយមកសេដ្ឋីនីបានរៀបចំជាកូនខ្ទមថ្មមួយនៅពីលើទីនោះ បង្គាប់ក្រែងមនុស្សជំនាន់ក្រោយនៃគ្រួសាររបស់ខ្លួន មកជីកកកាយដី និងបានហាមប្រាមតគ្នាទុកទីនេះជាតំបន់ហាមឃាត់មិនអាចជីកកកាយឬរើសំណង់ចេញឡើយ។

សីមាចង្កៀងបួន ដែលត្រូវបានអាចារ្យសន្ធប់ឲ្យនោះ បានធ្វើឱ្យខ្ទមក្លាយទៅជាទីកន្លែងមានឈ្មោះថា «ផ្ទះចង្កៀង» ដែលតុបតែងដោយចម្លាក់ថ្មីគឺចង្កៀងធំ មួយនៅពីលើ កម្ពស់ផុតក្បាលមនុស្ស។

រាប់រយឆ្នាំក្រោយមក ចម្លាក់នោះបានក្លាយទៅជាវត្ថុបុរាណគួរជាទីចាប់អារម្មណ៍របស់មនុស្សជំនាន់ថ្មី ។

ឆ្នាំ១៩៦៥……

យុវវ័យមួយក្រុមបានធ្វើដំណើរទៅដល់តំបន់ដែលធ្លាប់ជាវិមានឈើធំបង្អស់ក្នុងស្រុកនេះ។ នៅជំនាន់កាលជាយូរមកហើយឮថាជាកម្មសិទ្ធិនៃគ្រួសារអភិបាលមួយ ប៉ុន្តែឥឡូវនេះ ផ្ទះឈើបានរលាយបាត់រូបរាងដោយសារតែពេលវេលា បន្សល់នូវតែចម្លាក់ចង្កៀងថ្មដ៏ធំមួយដែលអ្នកទេសចរជាច្រើនចាប់អារម្មណ៍ជាខ្លាំង។

មានអ្នកខ្លះនិយាយអំពីរឿងនិទានពិតនៃចង្កៀងនេះ។

«ដោយសារចម្លាក់នេះធ្វើឡើងអំពីសារធាតុថ្មលាយជាមួយល្បាយគ្រួស និងមូលដ្ឋានរ៉ែកម្រជាច្រើនទៀតដែលមានភាពរឹងមាំ គួរឲ្យកត់សម្គាល់ អ្នកទាំងអស់គ្នាចាប់អារម្មណ៍យ៉ាងម៉េចដែរ?!»

លោកគ្រូ នរា បានសួរសំណួរបែបនេះ ទៅកាន់កូនសិស្សរបស់ខ្លួន។

កម្ពុះឆ្លើយឡើងភ្លាម៖

«ឮថាមានព្រាយមួយនៅជាប់ត្រូវគេសន្ធប់ពីក្រោមនេះ!»

វណ្ណដូខោកក្បាលកុម្ភៈខ្លោះ! កុម្ភៈក៏អេះក្បាលឈានថយក្រោយនៅពេលដែលមិត្តភក្តិនាំគ្នាសើចគិលឡើង  ប៉ុន្តែមិត្តម្នាក់ដែលពាក់វ៉ែនតាក្រាស់ជាងគេ មិនរវល់ជាមួយពួកក្រុមខ្លួនដែលកំពុងរីករាយនោះទេ គេជញ្ជក់មាត់ស្ញើចសរសើរចម្លាក់ចង្កៀងប្រេងមិនឈប់សោះ។

បាតដៃរបស់គេប៉ះពាល់ទៅលើរបស់នេះចុះឡើង រហូតដល់លោកគ្រូនរាប្រទះឃើញក៏ងាកទៅស្រែកឱ្យ៖

«សីហា! ហាមប៉ះពាល់ផ្ដេសផ្ដាស!»

សីហាដាក់ដៃមកវិញជាបន្ទាន់ មិនហ៊ានល្មើសនឹងការព្រមានរបស់គ្រូនរាឡើយ។ ទោះបីយ៉ាងណាទឹកមុខរបស់គេហាក់ដូចជាមានភាពចម្លែក។

យប់នោះក្រោយពេលដែលគ្រប់គ្នា ត្រលប់មកកាន់ទីស្នាក់អាស្រ័យវិញ វណ្ណដូឆ្លៀតឱកាសដែលគ្រប់គ្នាចូលសម្រាកអស់ គេក៏បានដើរសសៀរសសៀរមកក្បែរៗសីហាដែលកំពុងតែអង្គុយតែម្នាក់ឯងនៅពីមុខផ្ទះសំណាក់ឈើ ។

ផ្ទះនេះគឺជាកន្លែងដែលមន្ត្រីសាលាស្រុករៀបចំឡើងទទួលនិស្សិតក្រុមនេះពីក្រុងភ្នំពេញ។ គ្នាគេមានចំនួនដប់ពីរនាក់ សុទ្ធតែជាប្រុសៗទាំងអស់។

ដឹងថាមិត្តមកឈរក្បែរ សីហានិយាយខ្សឹបៗ៖

«លោកគ្រូនរាដែលសាលាខេត្តជាអ្នកចាត់ឱ្យមកនាំពួកយើងទស្សនកិច្ចភូមិដ្ឋានអភិបាលបុរាណ ឮគេថា គាត់បានដឹងនិងស្គាល់ប្រវត្តិនៃផ្ទះនោះតាំងពីកាលពីរាប់រយឆ្នាំក៏ដូចជាប្រវត្តិចម្លាក់ចង្កៀងថ្មដ៏ល្បីឈ្មោះមួយនេះដែរ ប៉ុន្តែគាត់មិនបាននិយាយលម្អិតអំពីរឿងរ៉ាវប្រវត្តិទាំងអស់ប្រាប់និស្សិតដែលមកធ្វើកម្មសិក្សាដូចដែលយើងគ្រោងទុកសោះ!»

សីហាថាប្រាប់វណ្ណដូទាំងដូចជាស្រពាប់ស្រពោនប្លែក។

«ហើយឯងដូចស្រងូតស្រងាត់ម៉េះកវីនិពន្ធសម្បូរស្នេហ៍?»

លើកនេះដឹងថាវណ្ណដូសួរឌឺហើយក៏សីហាមិនខឹងមិនរវល់តបត។ វណ្ណដូឃើញគេស្ងាត់វិញទៀតក៏និយាយបន្ត៖

«នៅពេលដែលត្រឡប់មកពីកម្មវិធីយើងព្រឹកមិញវិញ ឯងដូចជាស្រពោនៗម៉េចទេ?»

សីហាបានបក់ដៃឲ្យគេអង្គុយក្បែររួចឆ្លើយឡើងថា៖

«ខ្ញុំមានអារម្មណ៍ចម្លែកៗណាស់វណ្ណដូ! »

«ឯងជឿមករារឿងព្រាយហ្នឹងដែរ?!»

«តែឯងមានអារម្មណ៍ដូចម្ដេច? ឥឡូវនិយាយខាងវណ្ណដូឯងមុនមក!»

«ពេលដែលទៅកន្លែងចង្កៀងថ្មនោះហ្មែន? គ្មានអារម្មណ៍អ្វីទេ! គ្មានអីទាំងអស់! អូ! អាចមានអារម្មណ៍ថា លោកគ្រូបង្រៀនដូចជាលាក់ៗយើងមែន គាត់ប្រាប់តែអំពីនយោបាយនិងការរៀបចំចម្លាក់នេះឡើង ប៉ុន្តែគាត់មិនបានប្រាប់ថាតើចម្លាក់នេះពិតជាទាក់ទងនឹងពាក្យតំណាលចាស់ៗអមពីរឿងព្រាយនោះដោយសារអី?»

«ចុះវណ្ណដូឯងជឿគេនិយាយថាមានសន្ទប់ព្រលឹងខ្មោចដូចពាក្យចចាមអារ៉ាមដែរឬអត់? ប្រាប់ត្រង់មក!»

«សេរ៉ូ! ខ្ញុំអត់ចាប់អារម្មណ៍រឿងនោះទេ!»

«វណ្ណដូ! ប៉ុន្តែមានរឿងមួយ!» គេនិយាយត្រង់ណោះក៏ក្រឡេកឆ្វេងស្តាំដូចមានអ្នកណាតាមលប មកឮ លុះមិនឃើញមានក៏សីហាខ្សឹបខ្សៀវឡើង

«នៅពេលដែលខ្ញុំប៉ះចង្កៀងនោះពេលណា ខ្ញុំមានអារម្មណ៍ដូចជាវាមិនបាននៅរឹងឬក៏មាំ ដូចដែលយើងគិតទេ! ខ្ញុំមានអារម្មណ៍ដូចជាប៉ះសាច់សាច់មនុស្សណ៎ា!»

វណ្ណដូគេចមុខចេញបន្តិចតែបន្តសម្លក់ម្ចាស់សម្តី៖

«ពូកែស្រមើស្រមៃម៉េះសីហា?»

«អត់ទេ! អ៊ីចេះណ៎ា នៅពេលដែលខ្ញុំប៉ះចម្លាក់ថ្មនោះកាលណា ខ្ញុំស្រាប់តែដូចជាបាន ឮសំឡេង!»

«សំឡេង?»

«សំឡេងមនុស្សស្រីនិយាយមកកាន់ខ្ញុំ!»

សីហានិយាយដល់ត្រង់ណោះ វណ្ណដូធ្វើដៀងភ្នែកសម្លឹងបរិយាកាសជុំវិញខ្លួន ដែលពោរ ពេញទៅដោយសំឡេងចង្រិតសត្វល្អិតនានាយំជ្រៀតជ្រែកស្បៃរាត្រីកាល។

គេមិនមានការភ័យខ្លាចអ្វីទាំងអស់ ប៉ុន្តែគេបែរជាចង់ត្រូលខឹសីហា។

«អូយ ខ្លាចពេកហើយ!»

សីហានិយាយបន្តភ្លាម៖

«ខ្ញុំអត់ខ្លាចទេ ឯងកុំយល់ខុស! តែ...តែដូចជាមានអាថ៌កំបាំងដ៏ជ្រាលជ្រៅនៅក្នុងដួងចិត្តចង់ បកស្រាយនិយាយប្រាប់វណ្ណដូឯងក៏មិនកើត ខ្លួនឯងគិតថាយល់ក៏មិនយល់!»

«អីឯងបន្តស្រមៃរហូតយល់សិនទៅអ៊ីចឹងយើងទៅដេកហើយវ៉ី! យើងដឹងថា ឯងជាអ្នកនិពន្ធ រឿងប្រលោមលោក ហើយលោកឯងចូលចិត្តនិពន្ធរឿងបែបអបិយជំនឿអីហ្នឹង ប៉ុន្តែសម្រាប់ យើង មិនជឿរឿងអស់ទាំងហ្នឹងទេ យើងគ្រាន់តែជឿថា គ្រប់ទីកន្លែងតែងតែមានសាវតាររបស់ វា ហើយសាវតាររបស់វាគឺជារឿងពិតដែលពីរោះ មិនមែនរឿងប្រតិដ្ឋៗដូចដែលឯងទើបតែបាន និយាយអម្បាញ់មិញនេះទេ!»

សីហាដាក់វណ្ណដូមួយដៃផងធ្វើឱ្យមិត្តសើចក្អាកក្អាយចំអកឲ្យគេរួចចាកចេញទៅទាំងស្ទាប ងោកងុយ។

សីហានៅបន្តអង្គុយតែម្នាក់ឯង។

ចាប់តាំងពីពេលនោះមក ម្នាក់ៗដែលធ្លាប់ស្គាល់គេ មានអារម្មណ៍ថា សីហាហាក់មានភាពស្រពាប់ស្រពោនស្រងូតស្រងាត់មិនដែលនិយាយស្ដីរកអ្នកណាទាំងអស់ទោះបីកម្មសិក្សាទៅកន្លែងផ្សេងៗទៀតក្នុងខេត្តតែមួយក៏គេមិនបាននិយាយអ្វី ឬចូលរួមសូរនាំពិភាក្សាអ្វីជាមួយគេឯងឡើយ។

រយៈពេលប្រហែលជាមួយសប្ដាហ៍ក្រោយមកពេលដែលវណ្ណដូកំពុងតែញ៉ាំបបរយប់ជាមួយនឹងម្ដាយរបស់គេនៅក្នុងផ្ទះ ស្រាប់តែឮស្នូរគោះទ្វារ ។

«អ្នកណាមករកអីថ្មើនេះកូន?យប់ហើយ!»

«ចាំកូនទៅបើក»

វណ្ណដូមានតែម្ដាយមិនមានឪពុកនោះទេ ។ គេគ្រាន់តែបើកទ្វារស្រាប់តែឃើញស្ត្រីចំណាស់ម្នាក់ប្រកបដោយទឹកមុខស្រងូតស្រងាត់បង្ហាញខ្លួន។

«ក្មួយឈ្មោះវណ្ណដូមែនទេ?»

«បាទលោកអ៊ំ តើលោកអ៊ំអញ្ជើញរកអ្នកណា?!»

«អ៊ំគឺជាម្ដាយរបស់សីហា!»

«អូបាទ! តែគេមិននៅទីនេះទេអ៊ំ»

«សីហាគឺជាមិត្តភក្ដិក្មួយមែនទេ?!»

«អាចនិយាយអ៊ីចឹងបាន ប៉ុន្តែខ្ញុំមិនស្គាល់សីហាជិតស្និទ្ធប៉ុន្មានទេអ៊ំ! គេរៀនថ្នាក់ផ្សេងពីខ្ញុំប៉ុន្តែយើងឧស្សាហ៍ជួបគ្នា ជាពិសេសនៅវាល់ពេលធ្វើកម្មសិក្សា!»

«ហ៊ឹម ចាប់តាំងពីខែសីហាត្រឡប់មកពីមើលចង្កៀងថ្មនៅខេត្តនោះជាមួយក្មួយហើយ អ៊ំឃើញសភាពគេមានអាការៈប្លែកខ្លាំង!»

វណ្ណដូព្រិចភ្នែកគិតចុះឡើង។ សឹងតែភ្លេចអំពីរឿងបាលីចង្កៀងថ្មនិងរឿងដែលបាននិយាយគ្នាជាមួយសីហាកាលពីថ្ងៃនោះទៅហើយ។

«លោកអ៊ំអញ្ជើញចូលមកក្នុងផ្ទះសិនមក!»

គេបានណែនាំម្ដាយរបស់សីហាទៅឲ្យម្ដាយរបស់ខ្លួន។ ស្ត្រីចំណាស់ទាំងពីរក៏បានអង្គុយទល់មុខគ្នាដោយការរាប់អាន។

ទោះយ៉ាងណាប៉ុន្តែម្ដាយវណ្ណដូបានសង្កេតឃើញថា ម្ដាយរបស់សីហាមានទុក្ខព្រួយយ៉ាងជ្រាលជ្រៅ។

ដូច្នេះគាត់ចាប់ផ្ដើមវាចាឡើង៖

«បងអាចចាត់ទុកថាយើងជាមេម៉ាយដូចគ្នា និងមានកូនប្រុសម្នាក់ដូចគ្នាទៀត បើសិនជាមានរឿងអ្វីខាងខ្ញុំជួយបានសូមបងស្រីប្រញាប់ថាមកចុះ!»

ដូច្នេះហើយម្ដាយសីហាក៏ងក់ក្បាលហើយនិយាយខ្សឹបៗហ្មត់ចត់ទៅកាន់អ្នកទាំងពីរថា៖

«ខ្ញុំទើបតែមកពីស្រុករកបងប្អូនឲ្យគេជូនទៅគ្រូខ្មែរដើម្បីមើលផ្លូវងងឹត! ជោគជតារាសីរបស់កូនប្រុសខ្ញុំត្រូវគេនិយាយថា សីហាកូនខ្ញុំកំពុងរស់នៅជាមួយព្រាយចង្កៀងប្រេងមួយ!»